# រឿងរ៉ាវដំណើរការលូតលាស់នៃ "ដើមឈើ" មួយដើម



ដូច DeepSeek ដែរ ក្រុមហ៊ុនបច្ចេកវិទ្យាយូស៊ូ (ក្រុមហ៊ុន Unitree Robotics) ក៏បានក្លាយជាការពេញនិយមយ៉ាងខ្លាំងនៅនិទាឃរដូវនេះ ដោយសារតែមនុស្សយន្តរូបរាងមនុស្សរបស់វា។ ក្រុមហ៊ុនបច្ចេកវិទ្យាយូស៊ូ បានបង្ហាញខ្លួនជាញឹកញាប់នៅក្នុងការប្រកួតកីឡាអូឡាំពិករដូវរងាក្រុងប៉េកាំង និងកម្មវិធីរាត្រីសមោសរពិធីបុណ្យចូលឆ្នាំប្រពៃណីចិនជាដើម។ មនុស្សយន្តរបស់ក្រុមហ៊ុនបច្ចេកវិទ្យាយូស៊ូ មិនត្រឹមតែអាចជួយអ្នកទេសចរឡើងភ្នំថៃសានប៉ុណ្ណោះទេ ថែមទាំងអាចរាំ Yangge ទៀតផង ដែលអាចលេងក្បាច់គុនបាន និងអាចរាំរបាំបាន។ តើក្រុមហ៊ុននេះមានដើមកំណើតយ៉ាងណា ដែលត្រូវបានគេស្គាល់ថាជា "នាគតូចទាំងប្រាំមួយនៃទីក្រុងហាងចូវ"? តើវាក្លាយជាក្រុមហ៊ុនល្បីនៃប្រទេសចិន ដែលមានទំហំនាំចេញមនុស្សយន្តដ៏ធំបំផុតរបស់ពិភពលោក និងការលក់ឆ្កែយន្តដែលមានចំនួន ៦០% នៃចំនួនសរុបរបស់ពិភពលោកបានដោយរបៀបណា?

## តើលោក វ៉ាង ស៊ីងស៊ីង ជានរណា?

លោក វ៉ាង ស៊ីងស៊ីង ជាស្ថាបនិក និងជានាយកប្រតិបត្តិនៃក្រុមហ៊ុនបច្ចេកវិទ្យាយូស៊ូ កើតនៅឆ្នាំ ១៩៩០ ក្នុងគ្រួសារសាមញ្ញមួយនៅក្នុងទីក្រុងយ៉ូយ៉ាវ ក្រុងនីងពូ ខេត្តជឺជាំង។

លោក វ៉ាង ស៊ីងស៊ីង ចូលចិត្តផលិតផលអគ្គិសនីគ្រប់ប្រភេទតាំងពីលោកនៅក្មេង។ នៅពេលលោកចូលសិក្សានៅសាលាបឋមសិក្សា លោកចូលចិត្តមើលរឿងតុក្កតាបែបវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ហើយចាប់អារម្មណ៍ក្នុងការបង្កើតឧបករណ៍តូចៗនានាដោយដៃ។ នៅពេលមានអាយុ ១០ ឆ្នាំ វ៉ាង ស៊ីងស៊ីង បានឃើញមនុស្សយន្តរបស់ Boston Dynamics នៅក្នុងមន្ទីរពិសោធន៍ MIT នៅលើកញ្ចក់ទូរទស្សន៍ ហើយមានការចាប់អារម្មណ៍យ៉ាងខ្លាំងសម្រាប់មនុស្សយន្ត។ នៅពេលលោកសិក្សានៅសាលាអនុវិទ្យាល័យ លោកបានព្យាយាមបង្កើតម៉ាស៊ីនមីក្រូ Turbojet ដោយផ្ទាល់ខ្លួន។ នៅថ្នាក់ទី ១១ លោក វ៉ាង ស៊ីងស៊ីង បានព្យាយាមរៀនចំណេះដឹងអំពីថ្មពីសៀវភៅ និងទស្សនាវដ្តី ហើយទីបំផុតលោកបានបង្កើតថ្មដែលអាចសាកបានដោយសារធាតុគីមីដោយខ្លួនឯង។

ក្នុងឆ្នាំ ២០០៩ លោក វ៉ាង ស៊ីងស៊ីង ដែលមានអាយុ ១៨ ឆ្នាំត្រូវបានអនុញ្ញាតឱ្យចូលសិក្សាមុខជំនាញវិស្វកម្មមេកានិក និងអគ្គិសនីនៅមហាវិទ្យាល័យគ្រប់គ្រងមេកានិច និងស្វ័យ-ប្រវត្តិ នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាជឺជាំង។ ក្នុងអំឡុងពេលវិស្សមកាលរដូវរងានៃឆ្នាំសិក្សាថ្មីរបស់លោក លោកបានបង្កើតមនុស្សយន្តរូបរាងមនុស្សនៅលើតុដែលមានថ្លៃដើមជាង ២០០ យ៉ាន់ ដែលបង្ហាញពីការច្នៃប្រឌិតដ៏អស្ចារ្យរបស់ខ្លួន។

ក្នុងអំឡុងពេលវិស្សមកាលរដូវក្តៅឆ្នាំ ២០១០ លោក វ៉ាង ស៊ីងស៊ីង បានចំណាយប្រាក់ ៣០០ យ៉ាន់ ដើម្បីផលិតស្រោមដៃផ្តល់មតិឆ្លើយតបដោយខ្លួនឯង និងដៃឈ្លាសវៃ ព្រមទាំងបានបញ្ចប់គម្រោង "ឧបករណ៍ផ្តល់មតិឆ្លើយតបដោយកម្លាំងឌីជីថល" ហើយទីបំផុតបានបង្កើតស្រោមដៃផ្តល់មតិឆ្លើយតបតាមរយៈកម្លាំងអាចបត់បែនបានដោយសេរី និងកម្មវិធីអន្តរកម្មកម្លាំងជាក់ស្តែងនិម្មិត ៣D។ នៅក្នុងខែមេសា ឆ្នាំ ២០១១ លោក វ៉ាង ស៊ីងស៊ីង បានដាក់ពាក្យសុំប៉ាតង់ដំបូងក្នុងជីវិតរបស់លោក គឺ "ឧបករណ៍ផ្តល់មតិឆ្លើយតបតាមរយៈកម្លាំងសេរីលើម្រាមដៃ"។

ក្នុងឆ្នាំ ២០១៣ លោក វ៉ាង ស៊ីងស៊ីង ត្រូវបានអនុញ្ញាតឱ្យចូលសិក្សានៅសាកលវិទ្យាល័យសៀងហៃ ដើម្បីបន្តថ្នាក់អនុបណ្ឌិតផ្នែកវិស្វកម្មមេកានិច។ ក្រោមការណែនាំរបស់សាស្ត្រាចារ្យរបស់លោក លោកបានបង្កើតមនុស្សយន្តជើងបួន XDog ដោយបង្កើតគំរូសម្រាប់មនុស្សយន្តជើងបួនដែលមានតម្លៃទាប និងមានប្រសិទ្ធភាពខ្ពស់។ ក្នុងឆ្នាំ ២០១៥ ពឹងផ្អែក XDog លោកបានឈ្នះរង្វាន់ទីពីរនៅក្នុងការប្រកួតរចនារ៉ូបូតសៀងហៃ ហើយបានឈ្នះរង្វាន់ ៨ ម៉ឺនយ៉ាន់ នេះជាប្រាក់ដើមដំបូងរបស់លោក។

ទោះបីជាXDogមិនទទួលបានការវិនិយោគភ្លាមៗក៏ដោយ ប៉ុន្តែវាបានជួយលោក វ៉ាង ស៊ីងស៊ីង ទទួលបានឱកាសការងារពីក្រុមហ៊ុន DJI។ ក្នុងឆ្នាំ ២០១៦ លោកបានចូលធ្វើការក្នុង DJI បន្ទាប់ពីបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត ប៉ុន្តែលោកបានលាលែងពីតំណែងដើម្បីចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួនត្រឹមតែរយៈ-ពេល ២ ខែ។ ក្រោយទទួលបានការវិនិយោគសរុបចំនួន ២ លានយ៉ាន់ លោក និងសមាជិកក្រុមទាំងពីរបានបង្កើតក្រុមហ៊ុនបច្ចេកវិទ្យាយូស៊ូនៅទីក្រុងហាងចូវ ដោយផ្តោតលើការស្រាវជ្រាវ និងការប្រើប្រាស់មនុស្សយន្តជើងបួន ដែលមានប្រសិទ្ធភាពខ្ពស់ និងមនុស្សយន្តរូបរាងមនុស្ស។

## តើយូស៊ូជា "ដើមឈើ" ប្រភេទណា?

នៅក្នុងការិយាល័យរបស់លោក វ៉ាង ស៊ីងស៊ីង មានគំរូមនុស្សយន្តជំនាន់ទីមួយនៃក្រុមហ៊ុនបច្ចេកវិទ្យាយូស៊ូដាក់តាំងបង្ហាញ។ ពីគំរូដែលមិនទាន់ពេញលេញនេះ យើងអាចមើលឃើញគន្លងនៃការផ្លាស់ប្តូរ និងការធ្វើឱ្យប្រសើរឡើងរបស់ក្រុមហ៊ុនបច្ចេកវិទ្យាយូស៊ូ ពីការធ្វើត្រាប់តាមទៅជាការច្នៃប្រឌិតឯករាជ្យ ពីគំរូមន្ទីរពិសោធន៍ទៅជាផលិតផលដែលលក់ដាច់បំផុតទូទាំងពិភពលោកក្រុមហ៊ុនបច្ចេកវិទ្យាយូស៊ូបន្តផ្លាស់ប្តូរការច្នៃប្រឌិតមន្ទីរពិសោធន៍ទៅជានិន្នាការទូលំទូលាយក្នុងការអភិវឌ្ឍឧស្សាហកម្ម។

នៅដើមដំបូងនៃបង្កើតអាជីវកម្ម លោក វ៉ាង ស៊ីងស៊ីង និងក្រុមការងារបានចូលធ្វើការនៅក្នុងឃ្លាំងរថយន្តតូចមួយ ហើយធ្វើការលើការស្រាវជ្រាវទាំងយប់ទាំងថ្ងៃ។ ដើម្បីសន្សំការចំណាយ ពួកគេថែមទាំងបង្កើតគ្រឿងបន្លាស់ដោយខ្លួនឯងទៀតផង។ ទោះបីជាមានស្ថានភាពលំបាកយ៉ាងណាក៏ដោយ លោក វ៉ាង ស៊ីងស៊ីង ជឿជាក់យ៉ាងមុតមាំថា មនុស្សយន្តជើងបួននឹងមានលទ្ធភាពប្រើប្រាស់ទូលំទូលាយនាពេលអនាគត។

នៅឆ្នាំ ២០១៧ ក្រុមហ៊ុនបច្ចេកវិទ្យាយូស៊ូបានបញ្ចេញឆ្កែយន្តដំបូងរបស់ខ្លួនឈ្មោះ Lai-kago ដែលបានបើកទីផ្សារយ៉ាងឆាប់រហ័សជាមួយនឹងតម្លៃទាប និងប្រសិទ្ធភាពខ្ពស់។ ចាប់តាំងពីពេលនោះមក ក្រុមហ៊ុនបានដំណើរការផលិត-ផលធ្វើឱ្យប្រសើរឡើងជាបន្តបន្ទាប់ដូចជា Go១ ហើយបានលេចចេញជាបណ្តើរៗនៅក្នុងឧស្សា-ហកម្មនេះ។

នៅខែឧសភា ឆ្នាំ ២០២៤ នៅពេលដែលមនុស្សយើងនៅតែជជែកដេញដោលគ្នាយ៉ាងក្តៅគគុកថា តើមនុស្សយន្តរូបរាងមនុស្សអាចចូលទៅក្នុងផលិតកម្ម និងជីវិតមនុស្សបាននោះ ក្រុមហ៊ុនបច្ចេកវិទ្យាយូស៊ូបានបញ្ចេញមនុស្សយន្តរូបរាងមនុស្ស G១ តែម្តង។ នេះជាលើកទីមួយដែលតម្លៃមនុស្សយន្តរូបរាងមនុស្សមានជើងពីរត្រូវបានកាត់បន្ថយមកនៅក្រោម ១០ ម៉ឺនយ៉ាន់។ ការគ្រប់គ្រងថ្លៃដើមខ្លាំង+របកគំហើញបច្ចេកវិទ្យា ការលាយបញ្ចូលគ្នានៃការគិតបែបពាណិជ្ជកម្ម និងការគិតបែបអ្នកវិទ្យាសាស្ត្របានឈានទៅដល់ "ពេលវេលាយូស៊ូ" នៅក្នុងវិស័យមនុស្សយន្ត។

## ក្រុមហ៊ុនបច្ចេកវិទ្យាយូស៊ូត្រូវបានបង្កើតឡើងតិចជាង ៩ ឆ្នាំ ហើយបន្តការច្នៃប្រឌិតឥតឈប់ឈរ

ឆ្កែយន្ត និងមនុស្សយន្តមានលក្ខណៈផ្សេងៗគ្នាបានចេញ ពីការជំពប់ដួលទៅជាការរត់ជាលំដាប់ និងថ្លៃដើមធ្លាក់ចុះយ៉ាងខ្លាំង ហើយកំពុងចាប់ផ្តើមប្រើប្រាស់នៅក្នុងក្រុមហ៊ុន និងផ្ទះ។ សព្វថ្ងៃនេះ ក្នុងនាមជាស្តង់ដារមួយនៃឧស្សាហកម្មមនុស្សយន្តរបស់ប្រទេសចិន ក្រុមហ៊ុនបច្ចេកវិទ្យាយូស៊ូបានលើកកម្ពស់ការអភិវឌ្ឍខ្លួន និងឧស្សាហកម្មមនុស្សយន្តរបស់ប្រទេសចិនយ៉ាងឆាប់រហ័ស តាមរយៈរបកគំហើញបច្ចេកវិទ្យា សហកសាងអេកូឡូស៊ី និងការច្នៃប្រឌិតសេណារីយ៉ូកម្មវិធី។ នៅឆ្នាំ ២០២៤ ក្រុមហ៊ុនបច្ចេកវិទ្យាយូស៊ូបានប្រកាសពីប្រភពបើកចំហពង្រឹងមូលដ្ឋានកូដសិក្សាដោយទាក់ទាញអ្នកស្រាវជ្រាវជាងមួយម៉ឺននាក់ជុំវិញពិភពលោកឱ្យចូលរួមក្នុងការបង្កើតថ្មី។ ព័ត៌មានសាធារណៈបង្ហាញថា បច្ចុប្បន្ននេះ ក្រុមហ៊ុនបច្ចេកវិទ្យាយូស៊ូបានដាក់ពាក្យសុំប៉ាតង់ក្នុងប្រទេសចិន និងបរទេសជាង ១៨០ រួមទាំងប៉ាតង់ដែលមានការអនុញ្ញាតច្រើនជាង ១៥០ ហើយមនុស្សយន្តជើងបួនរបស់ក្រុមហ៊ុននេះមានចំណែកទីផ្សារសកល ៦០%។

ឈ្មោះជាភាសាអង់គ្លេសរបស់ក្រុមហ៊ុនបច្ចេកវិទ្យាយូស៊ូជា "Unitree" គឺជាការរួម-បញ្ចូលគ្នានៃ "Universe" និង "Tree" ដែលបង្ហាញពីលទ្ធភាពគ្មានដែនកំណត់នៃបច្ចេកវិទ្យា។ លោក វ៉ាង ស៊ីងស៊ីង បានប្រាប់អ្នកកាសែតថា ដោយសារតែការអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេក-វិទ្យា បច្ចេកវិទ្យាដែលពីមុនមិនអំណោយផលបានចូលដល់គេហដ្ឋានរបស់មនុស្សសាមញ្ញ គោលដៅរបស់យើងគឺ រក្សាភាពស្រស់ស្អាតប្រចាំថ្ងៃក្នុងជីវិត និងបំពេញតម្រូវការជីវភាពរស់នៅរបស់មនុស្ស ដើម្បីបំភ្លឺដើមឈើបច្ចេក-វិទ្យាមួយសម្រាប់មនុស្សជាតិ៕



រូបថតដោយស៊ីនហួ

អ្នកនិពន្ធភាសាចិន៖ RAN XIULAN អ្នកនិពន្ធភាសាខ្មែរ៖ LI ZHA SHEN YAN រចនារូបភាព៖ SUN YONGGANG